# ការអនុវត្តច្បាប់ក្រៅដែនដី (extraterritorial law enforcement)

ជាធម្មតា ការអនុវត្តច្បាប់ជាតិ មានប្រសិទ្ធភាព ឬត្រូវបានអនុញ្ញាតតែក្នុងរង្វង់ដែនដីទេ។ ក៏ប៉ុន្តែ ដោយសារទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ រដ្ឋនិងបុគ្គល និងទីកន្លែងបទល្មើស ការអនុវត្តច្បាប់ជាតិមួយ អាចលាតសន្ធឹងទៅក្រៅដែនដី កើតមានជៀងមិនរួច ហើយមានគោលការណ៍ច្បាប់មួយចំនួនគ្រប់គ្រងលើបញ្ហានេះ។

ការអនុវត្តច្បាប់ក្រៅដែនដី ជាសកម្មភាពអនុវត្តច្បាប់ ដែលសន្ធឹងក្រៅដែនដីនៃរដ្ឋ ដែលក្នុងនោះភ្នាក់ងារអនុវត្តច្បាប់ បានចូលរួមដឹកនាំផ្លូវការ (so engaged is officially headquartered)។ និយាយជាសាមញ្ញ វាជាការដែលរដ្ឋមួយ មានសិទ្ធិអនុវត្តអំណាចអនុវត្តច្បាប់ក្នុងដែនដីនៃរដ្ឋអធិបតេយ្យណាមួយទៀត។

ពាក្យថា «ក្រៅដែនដី» វាមិនអាស្រ័យទៅលើទីតាំងនោះទេ។ វាអាចផ្អែកតាមច្បាប់ ឬសន្ធិសញ្ញាអន្តរជាតិ ដែលបានចែងកំណត់។ ជាក់ស្តែង កប៉ាល់ធ្វើដំណើរក្រោមទង់ជាតិនៃប្រទេសមួយ (មានសញ្ជាតិប្រទេសនោះ តាមរយៈការចុះបញ្ជី) ត្រូវបានចាត់ដូចជាដែនដី សម្រាប់ការអនុវត្តច្បាប់ ទោះបីកំពុងធ្វើដំណើរក្នុងសមុទ្រអន្តរជាតិក្តី (high sea)។

ជាដំបូង ការអនុវត្តនោះ វាអាស្រ័យទៅតាមទីកន្លែង ដែលជនល្មើសត្រូវបានឃាត់ខ្លួន។ ប្រទេសមួយចំនួន ដូចជានៅទ្វីបអឺរ៉ុប បានរៀបចំបង្កើតយន្តការជួយគ្នាក្នុងវិស័យព្រហ្មទណ្ឌ ដែលក្នុងនោះបង្កើតជា កាតព្វកិច្ចបដិកា (reciprocal obligation)។

ការប្រកាន់តាមគោលការណ៍បុគ្គលភាព ([personality](personality)) និងគោលការណ៍ការពារប្រយោជន៍ ([protective principle](protective principle)) ដើម្បីបង្កើតយុត្តាធិការ អាចនាំទៅរកការអនុវត្តច្បាប់ក្រៅដែនដី ដែលវាពិតជាស្មុគ្រស្មាញ។ ដើម្បីកាត់បន្ថយបញ្ហានេះ ប្រទេសអង់គ្លេស បានកម្រិតការអនុវត្តចំពោះបទល្មើសធ្ងន់ធ្ងរ បទមនុស្សឃាត និងក្បត់ជាតិ។

ករណីការតាមដេញចាប់ភ្លាមៗ (hot pursuit) ចេញពីដែនសមុទ្ររបស់ខ្លួន (territorial sea) ទៅចូលក្នុងដែនសមុទ្រផ្សេង ជាឧទាហរណ៍មួយនៃការអនុវត្តច្បាប់ក្រៅដែនដី (Eugene McLaughlin and John Muncie, the Sage Dictionary of Criminology, 2nd Ed., Extraterritorial Law Enforcement, 2003, pp. 159-160)។